# វិធីសាស្ត្រគ្រប់គ្រង

# ចេកពងមាន់

# ក្រោយពេលប្រមូលផល




មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
Centre d'Etude et de Développement Agricole Cambodgien

វិទ្យាស្ថានអន្តរជាតិដើម្បីស្តារជនបទឡើងវិញ
International Institute of Rural Reconstruction



ឧបត្ថម្ភដោយ មូលនិធិ ម៉ាកណាយ
Funded by McKnight Foundation


## ១) ការប្រមូលផល

ការប្រមូលផលចេកពងមាន់ធ្វើឡើងក្រោយពី :

- ទំលាក់ត្រយូងអស់រយៈពេលពី ១ ខែ ទៅ ១ ខែ ១០ ថ្ងៃ
- មានអាយុសមស្រប ហើយផ្លែរបស់វាលប់ជ្រុង ( មូល)
- សំបកផ្លែរបស់វាស្ដើងរលោង និងមានឡើងម្សៅ
- ផ្លែរបស់វាចាប់ប្រែពណ៌ពីបៃតងទៅលឿង





- ការប្រមូលធ្វើឡើងនៅពេលស្រស់ទឹកសន្សើម ភ្លៀង ដើម្បីជៀសវាងការឆាប់ប្រេះ ឬស្អុយរលួយ
- ប្រើកាំបិតផ្គាក់មុត ដោយចាប់ផ្ដើមកាប់ពាក់កណ្ដាលដើម ឱ្យបាក់ដើមជិតដាច់ រួចចាប់ចុងស្ទងឱ្យជាប់ ទើបកាត់ផ្ដាច់ពីដើម
- កាត់រួចត្រូវដាក់ស្ទងបញ្ឈរដោយមានបង្អែក ឬក៏ចងព្យួរវាឱ្យស្រក់ជ័រក្នុងម្លប់ ហើយត្រូវប្រយ័ត្នកុំឱ្យប៉ះទង្គិចផ្លែ ពីព្រោះវាឆាប់រលាករលួយណាស់។
- យើងគួរប្រមូលផលនៅម៉ោង ៩ ព្រឹក ដល់ម៉ោង ៣ រសៀល ព្រោះពេលនេះវាចេញជ័រតិច ហើយអាចកាត់បន្ថយការខូចខាតដោយសារការប្រឡាក់ជ័រ។

## ២) ការតំរឹម និងសំអាត

- តំរឹមស្ទងឱ្យស្មើគ្នា (ប្រវែង ១ តឹក) ជៀសវាងកុំឱ្យគល់ស្ទងនៅសល់វែងពេកពីព្រោះវាធ្ងន់ និងមានប៉ះទង្គិចលើស្ទងផ្សេងទៀត
- យកក្រណាត់ទន់ជូតសំអាតដោយថ្នមៗ បើមានប្រឡាក់ដីលើ ផ្លែ
- កាត់ផ្លែ ឬស្និតណាដែលប្រេះ ឬស្អុយចេញដើម្បីការពារការឆ្លងទៅផ្លែផ្សេងទៀត។



## ៣) ការដឹកជញ្ជូន

- ការដឹកជញ្ជូន គឺចងកាងម៉ូតូដោយប្រុងប្រយ័ត្នកុំឱ្យវាយោលប៉ះគ្នា
- ចងព្យួរក្នុងទ្រុងឡានដោយមានដង្កៀ កៀបចុង និងដើមទងកុំឱ្យវាយោលទង្គិចគ្នា
- យើងអាចប្រើប្រាស់បាវក្រដាស/ក្រចៅគ្របដើម្បីចៀសវាងការប្រឡាក់ដី។



## ៤) ការស្តុកទុក

- ចេកពងមាន់អាចរក្សាទុកពី ៥ ទៅ ១២ ថ្ងៃ (គឺមិនឱ្យវាទុំ) ដោយគ្រាន់តែចងចុងស្ទងឡើងលើនៅកន្លែងម្លប់ត្រជាក់ ដូចជាក្រោមផ្ទះ ឬរោងសំរាប់ស្តុកតែម្តង ហើយឧស្សាហ៍ពិនិត្យមើល បើសំបកផ្លែរបស់វាស្រពាប់ ត្រូវយកកូនស្បោងដាក់ទឹក ហើយចងភ្ជាប់ នៅគល់ស្ទងរបស់វា។





## ៥) ការបន្ទុំ

- មុនពេលបន្ទុំ ត្រូវរក្សាទុករយៈពេល ២ ថ្ងៃសិន ដើម្បីឱ្យស្ងិតសណ្តង់ និងកុំឱ្យវារលួយ
- ការបន្ទុំចេកពងមាន់ធ្វើឡើងទាំងស្ទងតែម្តង ដោយគ្រាន់តែយកក្រណាត់ស្តង់ ឬស្បោងប្លាស្ទិករុំវាឱ្យជិត រួចដុតធូប ឬសារធាតុដែលមានផ្សែងច្រើន ហើយមានក្លិនក្រអូប ឬក៏ប្រើថ្មស្អុយតែម្តង (គុណភាព និងក្លិនមិនល្អ)
- ម្យ៉ាងទៀត យើងអាចយកវាទៅបន្ទុំក្នុងពាងធំមួយ ដោយយកស្លឹកឈើដូចជា ទំពូង អំពិលទឹក ម្រុំ អង្គាដី។ល។ ដែលហាលថ្ងៃស្រពោនរយៈពេល ១ ម៉ោង មកដាក់ចន្លោះស្ទង ឬផ្លែរបស់វា រួចដុតធូប ៣ ទៅ ៤ សរសៃ ក្នុងរយៈពេល ២ ថ្ងៃ ចេកទុំដោយមានគុណភាពល្អ និងក្លិនក្រអូប។




---

**កសិករមានបទពិសោធន៍ និង បានធ្វើការសាកល្បង**

ញៀត វណ្ណា ពត បញ្ញារិទ្ធិ ជាម សារេត និង នេត សុខ